# សុន្ទរកថា

# ឯកឧត្តម វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបសមិទ្ធិផលការងារឆ្នាំ២០១៣

របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

ថ្ងៃទី **១៩ ខែ** មិនា ឆ្នាំ២០១៤ សណ្ឋាគារ អប្សរាអង្គរ ខេត្តសៀមរាប

-សូមគោរព លោកវេជ្ជ. ម៉ូ ម៉ូ តាក់ គូជី (Dr. Momoe Takeuchi) តំណាងអង្គការសុខភាព ពិភពលោកប្រចាំកម្ពុជា

-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងអង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និង ម្ចាស់ជំនួយទាំងអស់ ព្រមទាំងសមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ជាទីមេត្រី

ក្នុងនាមក្រសួងសុខាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ថ្ងៃនេះខ្ញុំមានមនោសញ្ចេតនារំភើបរីករាយ ឥតឧបមា និងមានកិត្តិយសដ៏ឧត្តុងឧត្តម ដែលបានចូលរួមក្នុងពិធីបើកសន្និបាតបូកសរុបសមិទ្ធផលការងារ ឆ្នាំ២០១៣ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ខ្ញុំសូមពាំនាំនូវការសាកសួរសុខទុក្ខ និង នឹករលឹកដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចអគ្គមហាសេនាបតី តេជោហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជូនចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ទាំងអស់ដែលមានវត្តមាននៅក្នុងឱកាសនេះ។

ជំងឺគ្រុនចាញ់ គ្រុនឈាម ជំងឺប៉ារ៉ាស៊ីត និងជំងឺបង្កដោយវីរុសមួយចំនួនទៀត ដែលចំលងដោយមូស គឺជាបញ្ហាអាទិភាព ក្នុងចំណោមជំងឺឆ្លងនានាឈានមុខគេនៅក្នុងប្រទេសកម្ពុជា ដែលក្រសួងសុខាភិបាល កំពុងតែយកចិត្តទុកដាក់ក្នុងការប្រយុទ្ធ ឬលុបបំបាត់ ក្នុងនោះដូចជា ជំងឺគ្រុនចាញ់ គ្រុនឈាម ជាជំងឺដែល ប្រជាជន-សហគមន៍ស្គាល់ឬ ដឹងឮជាសាធារណៈ ក៏ប៉ុន្តែជំងឺខ្លះ ដូចជា ជំងឺដង្កូវព្រូនតូចៗ ដែលសំងំនៅ ត្រាំត្រែង (អង់ដេមិក) នៅក្នុងប្រជាជនកម្ពុជាជាយូរយារណាស់មកហើយនោះ មិនសូវមានរោគសញ្ញា ដែលយើងអាចស្គាល់អត្តសញ្ញាណជាទូលំទូលាយដោយងាយបានទេ ទោះបីជំងឺទាំងនោះនៅតែជាបញ្ហា សុខភាពសាធារណៈ អាចនាំឱយប៉ះពាល់ដល់ស្ថានភាពសុខភាពប្រជាជន ជាពិសេស ស្ថានភាពអាហា

រូបត្ថម្ភ ដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពមាតា និងកុមារក៏ដោយ។ រាជរដ្ឋាភិបាលជានិច្ចកាលបានឧបត្ថម្ភ គាំទ្រដល់សកម្មភាពប្រយុទ្ធ ឬលុបបំបាត់ជំងឺទាំងនេះ តាមរយៈកម្មវិធីជាតិចំនួន៣គឺ: ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម និងជំងឺដង្កូវព្រូន។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើមដោយផ្ទាល់ឱ្យក្រសួងសុខាភិបាលរៀបចំ និងដាក់ឱ្យដំណើរ ការផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ ២០១១-២០២៥។

លោកជំទាវ ឯកឧត្តម លោក លោកស្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរ ចំពោះបុគ្គលិកនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ បុគ្គលិកកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់-គ្រុនឈាម និងដង្កូវព្រូនតាមរាជធានី-ខេត្តនានា និងអង្គការជាដៃគូទាំងអស់ ដែលបានជួយគាំទ្រកម្មវិធីជាតិទាំង៣ លើផ្នែកបច្ចេកទេស និងថវិកាក្នុងការព្យាបាល-ការការពារ ការអប់រំសុខភាព និងការតាមដានស្រាវជ្រាវវាយតំលៃ។ ជាមួយគ្នានេះ ខ្ញុំក៏សូមអរគុណ និងវាយតម្លៃខ្ពស់ចំពោះស្ថាប័នពាក់ព័ន្ធអាជ្ញាធរមូលដ្ឋាន ដែលបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងសហការគ្នាគាំទ្រកម្មវិធីជាតិទាំងនេះរហូតទទួលបានជោគជ័យ។

ខ្ញុំសូមចូលរួមអង្គសន្និបាតនូវមតិមួយចំនួនដូចតទៅ:

**ទី១**-ទោះបីកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បានរួមចំណែកដល់រាជរដ្ឋាភិបាលក្នុងការសំរេចសូចនាករស្នូលរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សឆ្នាំ២០១៥ បានក្នុង ៣ឆ្នាំមុនកាលកំណត់ក្នុងនោះ មានការកាត់បន្ថយអត្រាស្លាប់ដោយគ្រុនចាញ់បានយ៉ាងច្រើនក្នុងពេលថ្មីៗនេះក៏ដោយ ក៏យើងនៅមានផ្លូវដ៏វែងដែលយើងត្រូវបន្តដើរតទៅទៀតក្នុងការអនុវឌ្ឍន៍ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឱ្យបាននូវឆ្នាំ២០២៥។

**ទី២**-ចំពោះការអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់នៅមូលដ្ឋាន ខ្ញុំសូមអំពាវនាវឱ្យមានការចូលរួមរបស់ម្ចាស់ការដ្ឋាន កសិកម្ម-ឧហ្សាហកម្ម-រ៉ែ និងគមនាគមន៍ដើម្បីធ្វើយ៉ាងណាឱ្យពលករទាំងអស់ជា ពិសេសពលករចល័តបានទទួលព័ត៌មានត្រឹមត្រូវស្តីពីជំងឺគ្រុនចាញ់ ក៏ដូចបានទទួលសេវាមានគុណភាពក្នុងការធ្វើរោគវិនិច្ឆ័យ-ព្យាបាលជំងឺនេះឱ្យបានទាន់ពេលវេលាដោយមិនចាំបាច់ឱ្យពួកគាត់បង់ថ្លៃសេវា។ ទន្ទឹមនឹងនោះត្រូវបន្តពង្រីកសហការជាមួយ

សេវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រឯកជន ក្នុងការពិនិត្យព្យាបាលជំងឺគ្រុនចាញ់ និងជាមួយអ្នកលក់មុង ដើម្បីបង្កើនអត្រាប្រើប្រាស់មុងជ្រលក់ថ្នាំឱ្យកាន់តែទូលំទូលាយ ។

ទី៣~គ្រប់ខេត្ត-ក្រុង សូមរៀបចំទិវាពិភពលោកប្រយុទ្ធជំងឺគ្រុនចាញ់ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៤ ដោយសហការជិតស្និទ្ធជាមួយអាជ្ញាធរដែនដី វិស័យពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ។

ទី៤~សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៩ របស់ក្រសួងសុខាភិបាលមានគោលបំណង ហាមឃាត់ការនាំចូល-ផលិត-ចរាចរឱសថគ្រុនចាញ់ដែលផ្អែកលើអារតេមិស៊ីនីនតែមួយមុខត្រូវបាន អនុវត្តរយៈកាលច្រើនឆ្នាំកន្លងមក ហើយទៅអនាគតមានតែមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រទេ ដែលក្រសួងអនុញ្ញាតឱ្យចុះបញ្ជីកាឱសថព្យាបាលគ្រុនចាញ់ ហេតុនេះ សូមអង្គភាពពាក់ព័ន្ធ ជាពិសេសនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង គ្រប់គ្រង តាមដានចរាចរឱសថគ្រុនចាញ់ នៅក្នុងទីផ្សារឱ្យមានប្រសិទ្ធភាពដោយសហការយ៉ាងជិតស្និទ្ធិជាមួយ មជ្ឈមណ្ឌលជាតិ និងអង្គភាពពាក់ព័ន្ធនានា ដូចជា រដ្ឋបាលមូលដ្ឋាន និងអង្គភាពនគរបាលជាដើម ។

ទី៥~ចំពោះជំងឺគ្រុនឈាមទោះ អង្គការសុខភាពពិភពលោកកត់សំគាល់ថា ការផ្ទុះរាតត្បាតជំងឺនេះតែង កើនមានក្នុងប្រទេសនីមួយៗក្នុង ៣-៥ឆ្នាំ ហេតុនេះទោះបីចំនួនករណីគ្រុនឈាមក្នុងរយៈពេលជាង២ ខែកន្លះដើមឆ្នាំ២០១៤ នេះករណីគ្រុនឈាមមានតិចជាងរយៈពេលដូចគ្នាឆ្នាំ២០១៣ ប្រហែល ៨-៩ ដងក៏ដោយ ក៏យើងត្រូវបន្តប្រុងប្រយ័ត្នជានិច្ច ក្នុងនោះត្រូវត្រៀមលក្ខណៈឆ្លើយតបបន្ទាន់ក្នុងករណី មានការផ្ទុះរាតត្បាត ។ វិធានការចាំបាច់គ្មានទឹកដក់ គ្មានដង្កូវទឹក គ្មានមូសខ្លា ។

ទី៦~ចំពោះជំងឺដង្កូវព្រូន សូមបន្តធ្វើសកម្មភាពដោយផ្តល់អាទិភាពដល់ការរក្សាអត្រាគ្របដណ្តប់ការ ផ្តល់ថ្នាំទំលាក់ព្រូននៅតាមសាលារៀនឱ្យនៅខ្ពស់ជាង ៩០% ហើយសូមការពង្រីកអត្រាគ្របដណ្តប់ សំរាប់ស្ត្រីក្នុងវ័យបន្តពូជ ដើម្បីរួមចំណែកជាមួយកម្មវិធីអាហារូបត្ថម្ភមាតា និងកុមារ ។

ជាថ្មីម្តងទៀតខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះបណ្តាប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ព្រមទាំងស្ថានប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដែលបានខិតខំប្រឹងប្រែងផ្តល់ការគាំទ្រ ទាំងស្មារតី សំភារៈ និងថវិកាដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ រហូតទទួលបានលទ្ធផលល្អប្រសើរកន្លងមក ។ ខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំផងដែរថា ម្ចាស់ជំនួយ និងដៃគូ ទាំងអស់នឹងនៅតែបន្តជួយដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធិថែមទៀត ដើម្បីរួមកាត់បន្ថយអត្រាឈឺ/ស្លាប់ដោយសារជំងឺគ្រុនចាញ់ គ្រុនឈាម ដង្កូវព្រូន និងជំងឺផ្សេងៗទៀតដែលចំលងដោយមូស។

ជាទីបញ្ចប់ ក្នុងនាមក្រសួងសុខាភិបាល និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមជូនពរបវរមហាប្រសើរចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិក សមាជិកានៃអង្គពិធីទាំងមូល សូមប្រកបដោយពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបើក** សន្និបាតបូកសរុបលទ្ធផលការងារមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ឆ្នាំ២០១៣ ចាប់ពីពេលនេះតទៅ។

សូមអរគុណ